# ព្រឹត្តិបត្រប្រចាំត្រីមាសទី៣

ទឹកស្អាតសម្រាប់មនុស្សគ្រប់រូប

ខែកក្កដា ដល់ ខែកញ្ញា ឆ្នាំ២០២១

## បច្ចុប្បន្នភាពសមាគម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ទ.ក) ជាអង្គការឯករាជ្យប្រមូលផ្តុំអ្នកផ្គត់ផ្គង់ទឹកស្អាតទាំងអស់នៅកម្ពុជា ដើម្បីបម្រើផលប្រយោជន៍រួមរបស់សមាជិកសមាគមដោយមិនស្វែងរកប្រាក់ចំណេញជាឯកជន និងមិនចំណុះឱ្យគណបក្សនយោបាយ។

សមាគមត្រូវបានបង្កើតឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ និងបានចុះបញ្ជីជាផ្លូវការនៅក្រសួងមហាផ្ទៃ នៅថ្ងៃទី៦ ខែសីហា ឆ្នាំ០១២។ សមាគមមានគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់នៅក្នុង វិស័យផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។ ទស្សនៈវិស័យរបស់សមាគមគឺ ផ្តល់នូវសេវាកម្មផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជនប្រកបដោយគុណភាព និងអនាម័យស្របតាមស្តង់ដាទឹកស្អាតថ្នាក់ជាតិនៅគ្រប់តំបន់ក្នុងព្រះរាជាណាចក្រកម្ពុជា។

ត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា មានសមាជិកសរុប ២៨៣**ស្ថានីយ និងក្រុមហ៊ុន**។ ក្នុងនោះមាន **២៥៤** ជាស្ថានីយផ្គត់ផ្គង់ទឹកស្អាតនៅទូទាំង ២៣រាជធានីខេត្ត-ក្រុង និង២៩ ជាក្រុមហ៊ុនផ្គត់ផ្គង់សម្ភារៈលើវិស័យទឹកស្អាត។

## កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

នៅក្នុងត្រីមាសទី៣នេះ ក្រុមប្រឹក្សាភិបាលបានរៀបចំកិច្ចប្រជុំចំនួន ៣លើក ក្នុងគោលបំណងផ្សេងៗគ្នាដែលមានដូចខាងក្រោយ៖

- លើកទី១ នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាភិបាល ដើម្បីពិភាក្សាលើលក្ខន្តិកៈរបស់សមាគមដែលបានកែសម្រួលដោយមន្ត្រី ក្រសួងមហាផ្ទៃ។ ជាលទ្ធផលនៃកិច្ចប្រជុំសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់បានឯកភាពគ្នាក្នុងការស្នើឱ្យដកចេញនៅ លក្ខខណ្ឌមួយចំនួនពាក់ព័ន្ធទៅនឹងនីតិបុគ្គលរបស់ក្រុមប្រឹក្សាភិបាល និងសម្រួលលើលក្ខខណ្ឌមួយចំនួន។ អង្គប្រជុំបានសម្រេចឱ្យ លោក ហម ងួន និង លោក សៀ សេងហ៊ាប តំណាងឱ្យក្រុមប្រឹក្សាភិបាល ទៅជួបពិភាក្សាជាមួយមន្ត្រីក្រសួងមហាផ្ទៃលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។






- លើកទី២ នៅព្រឹកថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ កិច្ចប្រជុំវិសាមញ្ញក្រុមប្រឹក្សាភិបាលសមាគម តាមប្រព័ន្ធអនឡាញ (Zoom Call)។ ក្រោយពីការពិភាក្សាយ៉ាងផុលផុសមក អង្គប្រជុំបានសម្រេចដូចខាងក្រោម លោក សៀ សេងហ៊ាប នឹងធ្វើការណាត់ជួបប្រជុំរវាង តំណាងខាងក្រសួងមហាផ្ទៃ និងថ្នាក់ដឹកនាំក្រុមប្រឹក្សាបាលសមាគម រួមមាន៖ លោក ឡេង ខៀវ លោក ហម ងួន និងលោក សៀ សេងហ៊ាប ដើម្បីពិភាក្សាស្តីពី«ការកែសម្រួលលក្ខន្តិកៈសមាគមដើម្បីចុះបញ្ជីសមាគមជានីតិបុគ្គលនៅក្រសួងមហាផ្ទៃ»។

  ២. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកក្រោយ សមាគមនឹងលើកយកបញ្ហាសមាជិកដែលមិនទាន់បានបង់ប្រាក់វិភាគទានប្រចាំឆ្នាំ២០២០ ជូនសមាគមដើម្បីពិភាក្សា និងសម្រេចលើសមាជិកភាពរបស់ពួកគាត់ដោយផ្អែកតាមគោលនយោបាយសមាជិកភាពរបស់សមាគម។

  ៣.ទាក់ទងទៅនឹងសំណើរបស់សមាជិកស្តីពី គុណភាពនៃផលិតផលរបស់ក្រុមហ៊ុនដែលជាសមាជិកសាមញ្ញរបស់សមាគម ក្រុមប្រឹក្សាភិបាលសម្រេចឱ្យសមាគមទាក់ទងទៅក្រុមហ៊ុនទាំងអស់ឱ្យធ្វើការផ្សព្វផ្សាយឯកសារបញ្ជាក់ពីផលិតផលរបស់ខ្លួនក្នុងបណ្តាញទំនាក់ទំនងសង្គម(Telegram Group and Messenger Group) របស់សមាគម។

  ៤.សមាគមបន្តផ្តល់វគ្គបណ្តុះបណ្តាលជូនសមាជិកបន្ថែមទៀត។

- លើកទី៣ នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០២១ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលសម្រាប់ត្រីមាសទី២ តាមប្រព័ន្ធអនឡាញ(Zoom Call) ក្នុងគោលបំណង៖

  ១. អនុម័តទៅលើកំណត់ហេតុកិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រីមាសទី១

  ២. របាយការណ៍រីកចំរើនប្រចាំត្រីមាសទី២ និងផែនការសកម្មភាពសម្រាប់ត្រីមាសទី៣

  ៣. របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី២ និងផែនការហិរញ្ញវត្ថុសម្រាប់ត្រីមាសទី៣

  ៤. របាយការណ៍បច្ចុប្បន្នភាព ហិរញ្ញវត្ថុរបស់សមាគម

  ៥. ពិនិត្យ និងសម្រេចលើសមាជិកភាពរបស់សមាជិក ដែលមិនទាន់បង់សមាជិកភាពឆ្នាំ២០២០

ជាលទ្ធផលក្រុមប្រឹក្សាភិបាលបាន៖

  - ឯកភាពតាមកំណត់ហេតុប្រជុំត្រីមាសទី១

○ ពិនិត្យ និងឯកភាពទៅលើរបាយការណ៍រីកចំរើន និងរបាយការណ៍ហិរញ្ញវត្ថុ របស់សមាគមប្រចាំត្រីមាសទី២ ផែនការសកម្មភាព និងថវិកាសម្រាប់ត្រីមាសទី៣។

សម្រេចជាឯកច្ឆន្ទ ក្នុងការចេញលិខិតជូនដំណឹងដល់សមាជិកដែលមិនទាន់បានបង់ប្រាក់វិភាគទានសមាជិកភាពជូនសមាគមសម្រាប់ឆ្នាំ២០២០ ដោយទុកពេលឱ្យពួកគាត់បង់ប្រាក់វិភាគទាននោះដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ជាកំហិត។ ចំពោះសមាជិកដែលមិនបានបង់ប្រាក់វិភាគទានតាមកាលកំណត់ នោះសមាគមនឹងដកសមាជិកភាពចេញពីសមាគម ហើយសមាគមនឹងធ្វើលិខិតជូនដំណឹងអំពីការដកសមាជិកភាពនេះទៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

## កិច្ចប្រជុំសួរសុខទុក្ខជាមួយសមាជិក

### កិច្ចប្រជុំសួរសុខទុក្ខសមាជិកជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតនៅតាមបណ្តាខេត្ត

នៅក្នុងត្រីមាសទី៣ សមាគមបានរៀបចំកិច្ចប្រជុំសួរសុខទុក្ខសមាជិកបានចំនួន ២លើកតាមប្រព័ន្ធអនឡាញ (Zoom Call)។ កិច្ចប្រជុំសួរសុខទុក្ខសមាជិកមានគោលបំណង ខាងក្រោម៖

១. បង្កើនទំនាក់ទំនងរវាងសមាជិក និងថ្នាក់ដឹកនាំសមាគម ក៏ដូចជារវាងសមាជិក និងសមាជិក

២. ស្វែងយល់ពីការរីកចម្រើន បញ្ហាប្រឈមដែលសមាជិកបាននឹងកំពុងជួបប្រទះ និងស្វែងរកដំណោះស្រាយរួមគ្នា

៣. ចែករំលែកចំណេះដឹង បទពិសោធន៍ និងព័ត៌មានថ្មីៗ

លើកទី១ នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ សម្រាប់សមាជិកនៅខេត្តព្រៃវែង និងខេត្តស្វាយរៀង។ កិច្ចប្រជុំនេះ មានអ្នកចូលរួមចំនួន ២៥នាក់(ស្រី១២នាក់)រួមមាន៖ ក្រុមប្រឹក្សាភិបាល បុគ្គលិកសមាគម និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចំនួន ១០ស្ថានីយ។

លើកទី២ នៅថ្ងៃ ទី២៦ ខែសីហា ឆ្នាំ២០២១ សម្រាប់សមាជិកនៅខេត្តក្រចេះ ខេត្តមណ្ឌលគីរី និងខេត្តត្បូងឃ្មុំ កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន ៣០នាក់ (ស្រី ៥នាក់) រួមមាន៖ ក្រុមប្រឹក្សាភិបាលសមាគម បុគ្គលិកសមាគម ដៃគូអភិវឌ្ឍន៍(WASH-FIN) និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ចំនួន ១៣ស្ថានីយ។





ក្នុងកិច្ចប្រជុំសួរសុខទុក្ខសមាជិកទាំងពីរលើក សមាជិកបានលើកឡើងពីបញ្ហាមួយចំនួនដែលពួកគាត់បានជួបប្រទះក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ ដូចខាងក្រោម៖

- ការបង់ប្រាក់ថ្លៃប្រើប្រាស់ទឹកស្អាតរបស់អតិថិជនមានការយឺតយ៉ាវ
- ការប្រើប្រាស់ទឹកមានការថយចុះ
- ការធ្វើផ្លូវ ជួសជុលផ្លូវ និងដាក់លូ ធ្វើឱ្យខូចខាតបណ្តាញបំពង់ទឹកស្អាត
- កិច្ចសហការរវាងអាជ្ញាធរភូមិឃុំ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតនៅមានកម្រិត
- សមាជិកភាគច្រើនមិនទាន់មានឧបករណ៍តេស្តទឹកស្អាតប្រចាំថ្ងៃ
- ខ្វះទុនក្នុងការពង្រីកបណ្តាញបំពង់ទឹកស្អាត។

ជាការចូលរួម ក្រុមប្រឹក្សាភិបាលសមាគម បានអំពាវនាវឱ្យស្ថានីយផ្គត់ផ្គង់ទឹកស្អាតដែលមិនទាន់បានរៀបចំឧបករណ៍ តេស្តគុណភាពទឹកស្អាតប្រចាំថ្ងៃ ត្រូវពិចារណាទិញឧបករណ៍តេស្តគុណភាពទឹកស្អាតប្រចាំថ្ងៃ ដើម្បីធានាថាទឹកស្អាតដែលផលិតមកនោះគឺមានគុណភាពល្អស្របតាមគុណភាពទឹកស្អាតថ្នាក់ជាតិ ក៏ដូចជាការឆ្លើយតបទៅនឹង សជណ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

## កិច្ចប្រជុំសួរសុខទុក្ខសមាជិកសាមញ្ញ

ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានរៀបចំកិច្ចប្រជុំប្រចាំធមាសជាមួយសមាជិកសាមញ្ញដែលជាក្រុមហ៊ុនផ្គត់ផ្គត់សម្ភារៈលើវិស័យទឹកស្អាតជាលើកទី២ តាមប្រព័ន្ធអនឡាញ(Zoom Call) ដើម្បី ពិភាក្សាទៅលទ្ធផលនៃការ ប្រើប្រាស់ បណ្តាញទំនាក់ទំនងសង្គម (Telegram Group និង Messenger Group) សម្រាប់ការផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុន។

សមាគមបានបង្កើតបណ្តាញទំនាក់ទំនងសង្គម (Telegram Group និង Messenger Group) សម្រាប់ការផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុនដែលជាសមាជិកសាមញ្ញ កាលពីខែកមរា ឆ្នាំ២០២១) ។ កិច្ចប្រជុមលើកទី២នេះ មានអ្នកចូលរួមចំនួន ២៩នាក់ រួមមាន៖ ក្រុមប្រឹក្សាភិបាល បុគ្គលិកសមាគម សមាជិកសាមញ្ញមកពី ១៤ក្រុមហ៊ុន ។



ជាលទ្ធផលសមាជិកទាំងអស់ដែលចូលរួមបានសាទរ និងគាំទ្រ ចំពោះការបង្កើតឱ្យមានបណ្ដាញទំនាក់ទំនងសង្គម (Telegram Group និង Messenger Group) សម្រាប់ការផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុន។ សមាជិកទាំងអស់បានសំណូមពរសមាគមឱ្យជូនដំណឹងទៅក្រុមហ៊ុនទាំងអស់ប្រសិនបើសមាគមមានកម្មវិធីចុះសួរសុខទុក្ខសមាជិក តាមតំបន់ ឬវគ្គបណ្ដុះបណ្ដាល ជាមួយប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ព្រោះពួកគាត់អាចនឹងចូលរួមជាមួយសមាគមដើម្បីចែករំលែកពីផលិតផលរបស់ក្រុមហ៊ុន។

ជាការឆ្លើយតប សមាគមនឹងជូនដំណឹងទៅសមាជិកសាមញ្ញរាល់សកម្មភាពដែលមានការចូលរួមពីសមាជិកដែលប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត

## ការងារគម្រោង

### គម្រោងការពង្រឹងគណនេយ្យភាពរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតដើម្បីលើកកម្ពស់សេវាកម្មទឹកស្អាត (WaterAid)

ក្នុងត្រីមាសទី៣ ក្រោមជំនួយឧបត្ថម្ភពីអង្គការវ៉តធឺអេតកម្ពុជា លើគម្រោង «ការពង្រឹងគណនេយ្យភាពរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតដើម្បីលើកកម្ពស់សេវាកម្មទឹកស្អាត» សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជាបានអនុវត្តសកម្មភាពសំខាន់ដូចខាងក្រោម៖

#### ១. វគ្គបណ្ដុះបណ្ដាល

សមាគមបានសហការជាមួយមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកណ្ដាល បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី «តួនាទី និងការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងសហគមន៍ចំពោះសេវាទឹកស្អាត» ជូនដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនក្នុងខេត្តកណ្ដាល តាមប្រព័ន្ធអនឡាញ (Zoom Call)។ វគ្គបណ្ដុះបណ្ដាល មានអ្នកចូលរួមសរុបចំនួន ២៦នាក់ ក្នុងនោះមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចំនួន ១២ស្ថានីយ (១៧នាក់) មន្ត្រីរដ្ឋបាលស្រុកកណ្ដាលស្ទឹងចំនួន ២នាក់ មន្ត្រីមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកណ្ដាលចំនួន ៤នាក់ តំណាងអង្គការវ៉តធឺអេតកម្ពុជាចំនួន ១នាក់ និងបុគ្គលិកសមាគមចំនួន ២នាក់។



## ២. ការសិក្សាប្រមូលទិន្នន័យដើមគ្រា

សមាគមបានរៀបចំវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ(Zoom Call) ស្តីពី«ដំណើរការនៃការប្រមូលទិន្នន័យដើមគ្រា និងគាំទ្រជាបច្ចេកទេសនានា» ជូនដល់មន្ត្រីរដ្ឋបាលស្រុកកំពង់ត្រឡាច ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង និងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដើម្បីចុះប្រមូលទិន្នន័យពីអាជ្ញាធរមូលដ្ឋាន និងសហគមន៍។

កាសិក្សាប្រមូលទិន្នន័យដើមគ្រានេះមានគោលបំណងផ្តល់នូវព័ត៌មានដ៏សំខាន់សម្រាប់វាស់ស្ទង់ការផ្លាស់ប្តូរចំណេះដឹង និងឥរិយាបទរបស់អាជ្ញាធរមូលដ្ឋាន និងសហគមន៍ចំពោះសេវាកម្មផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ ហើយវាក៏ជាមូលដ្ឋានសម្រាប់ប្រៀបធៀបស្ថានភាពមុនពេល និងក្រោយអនុវត្តគម្រោង ព្រមទាំងសម្រាប់ធ្វើសេចក្តីសន្និដ្ឋានអំពីប្រសិទ្ធភាពនៃការអនុវត្តគម្រោងផងដែរ។

ជាលទ្ធផល ក្រុមការងាររដ្ឋបាលស្រុកទាំងបី (៣) បានប្រមូលទិន្នន័យពីឃុំចំនួន ១៨ឃុំ ដែលមានអ្នកចូលរួមសំភាសន៍ជាអាជ្ញាធរមូលដ្ឋាន (ភូមិ និងឃុំ) និងប្រជាជនសរុបចំនួន ២៩១នាក់ (ស្រី១២៥នាក់) ក្នុងនោះដែរអាជ្ញាធរមូលដ្ឋានមានចំនួន ១៤២។



## ៣. កិច្ចប្រជុំក្រុមការងារទឹកស្អាត និងអនាម័យខេត្ត

នៅក្នុងត្រីមាសទី៣ នេះបុគ្គលិកសមាគមបានចូលរួមក្នុងកិច្ចប្រជុំក្រុមការងារទឹកស្អាត និង អនាម័យចំនួនបី(៣)ដង កិច្ចប្រជុំនេះរៀបចំដោយក្រុមការងារទឹកស្អាត និងអនាម័យខេត្តកណ្តាលចំនួន ២ដង និងក្រុមការងារទឹកស្អាត និងអនាម័យខេត្តកំពង់ស្ពឺចំនួន ១ដង។ ជាងនេះទៅទៀត ក្រុមការងារទឹកស្អាត និងអនាម័យខេត្តទាំងពីរបានចុះឈ្មោះសមាគមទៅក្នុងក្រុមការងារទឹកស្អាត និងអនាម័យខេត្តផងដែរ។




## ៤. កិច្ចសហការ

ទន្ទឹមនឹងសកម្មភាពខាងលើសមាគមក៏បានធ្វើការទំនាក់ទំនងទៅក្រុមការងាររបស់អង្គការវ៉តធីអេតកម្ពុជា និងមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ ដើម្បីស្វែងរកកិច្ចសហការ និងការគាំទ្រ ចំពោះការស្នើសុំការអនុញ្ញាតពីរដ្ឋបាលស្រុកដើម្បីអនុវត្តគម្រោងនៅក្នុងស្រុកអង្គស្នួល ខេត្តកណ្តាល ស្រុកសំរោងទង និងស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។

## ៥. ការគាំទ្រដល់ការឧបត្ថម្ភធនលើការភ្ជាប់ទឹកស្អាតជូនគ្រួសារក្រីក្រ

គិតត្រឹមចុងត្រីមាសទី៣នេះ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួនបួន (៤) រួមមាន៖ ស្ថានីយទឹកស្អាតព្រៃករាំង ស្ថានីយទឹកស្អាត ហេង អៀម ស្ថានីយទឹកស្អាតក្តុល និងស្ថានីយទឹកស្អាតសាលាលេខ៥ បានទទួល និងយល់ព្រមគាំទ្រដល់ការឧបត្ថម្ភធនលើការតភ្ជាប់ទឹកស្អាតជូនគ្រួសារក្រីក្រ១ និងគ្រួសារក្រីក្រ២។ ជាលទ្ធផល គ្រួសារក្រីក្រចំនួន ៦៩គ្រួសារ (ដែលមានសមាជិក ប្រមាណ ២៩៥នាក់) បានភ្ជាប់សេវាទឹកស្អាតពីស្ថានីយទាំង៤ខាងលើ។

## ៦. ការកសាងសមត្ថភាពបុគ្គលិក

បុគ្គលិកសមាគមចំនួន ៤នាក់ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលចំនួនពីរ (២) គឺវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី«ប្រសិទ្ធភាពនៃការផ្តល់វគ្គបណ្តុះបណ្តាលលើប្រធានបទទឹកស្អាត និងអនាម័យ» និងវគ្គបណ្តុះបណ្តាលស្តីពី «ការត្រួតពិនិត្យតាមដាន ការវាយតម្លៃ និងការរៀនសូត្រ» ដែលរៀបចំដោយ WASH-SDO(ដៃគូរបស់អង្គការវ៉តធីអេតកម្ពុជា) និងអង្គការវ៉តធីអេតកម្ពុជាផ្ទាល់។




## គម្រោងគាំទ្រហិរញ្ញប្បទានលើបញ្ហាទឹក និងអនាម័យ (WASH-FIN)

ក្នុងត្រីមាសទី៣ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា និងគម្រោងការគាំទ្រហិរញ្ញប្បទានលើការងារទឹកស្អាត និងអនាម័យ (WASH-FIN) បានអនុវត្តសកម្មភាពសំខាន់ដូចខាងក្រោម៖

### ១. ការរកប្រភពទុនកម្ចីសម្រាប់ការពង្រីកសេវាកម្មផ្គត់ផ្គង់ទឹកស្អាត

នៅក្នុងត្រីមាសនេះ បុគ្គលិករបស់គម្រោងបានជួបទំនាក់ទំនងជាមួយស្ថានប័នមួយចំនួនដូចជា មីក្រូហិរញ្ញវត្ថុអម្រឹត ធនាគារកាណាឌីយ៉ា ធនាគារ SME និងធនាគារ WING ដើម្បីស្នើសុំកិច្ចសហការ និងគាំទ្រដល់វិស័យផ្គត់ផ្គង់ទឹកស្អាត។ គម្រោងក៏បាន រៀបចំផែនការអាជីវកម្មជូនស្ថានីយទឹកស្អាតមួយនៅក្នុងខេត្តព្រៃវែង ។ ដើម្បីជួយសម្រួលដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនក្នុងការទំនាក់ទំនង និងមានឯកសារគ្រប់គ្រាន់សម្រាប់ធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធ្វើការសិក្សាពីលទ្ធភាពផ្តល់កម្ចី។

### ២. វគ្គបណ្តុះបណ្តាល

ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២១ គម្រោងបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "**មូលដ្ឋានគណនេយ្យ និងការបង់ពន្ធ**" តាមប្រព័ន្ធអនឡាញ(Zoom Call)ដើម្បីជួយពង្រឹងសមត្ថភាព ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត១).ការកត់ត្រា និងទុកដាក់ប្រតិបត្តិការហិរញ្ញវត្ថុ ២).អាចកំណត់ជ្រើសរើសប្រព័ន្ធកត់ត្រាមួយដែលសមស្របទៅនឹងតម្រូវការ និងធនធាន ៣).អាចរៀបចំ និងពន្យល់របាយការណ៍ហិរញ្ញវត្ថុ ៤). ដឹងពីប្រភេទពន្ធដែលសហគ្រាសត្រូវបង់ និងដំណើរការនៃការបង់ពន្ធ។ វគ្គបណ្តុះបណ្តាលនេះមានស្ថានីយ ៥ដែលបានចូលរួម ១. ស្ថានីយទឹកស្អាត ខោ ប៊ុនហ៊ាត ២. ស្ថានីយទឹកស្អាតព្រែករាំង ៣. ស្ថានីយទឹកស្អាតបាភ្នំ ៤. ស្ថានីយទឹកស្អាតក្រូចឆ្មារ ៥. ស្ថានីយទឹកស្អាតចំការលើ) ក្នុងនោះមានអ្នកចូលរួមសរុបចំនួន ៨នាក់ (ស្រី៤នាក់)។







## ៣. ការសិក្សាផ្នែកបច្ចេកទេស

របាយការណ៍សិក្សាបច្ចេកទេសមាន គោលបំណងស្វែងយល់ និងវិភាគពីស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករ។ នៅត្រីមាសទី៣ ក្រុមការងារផ្នែកបច្ចេកទេសរបស់គម្រោងបានចុះសិក្សា និងរៀបចំរបាយការណ៍សិក្សាផ្នែកបច្ចេកទេសបានចប់សព្វគ្រប់ជូនដល់ស្ថានីយចំនួនពីរ (២) គឺស្ថានីយទឹកស្អាតក្រាំងចេក ស្ថានីយទឹកស្អាតចំការលើ។ បន្ថែមពីនេះទៀត ក្រុមការងារក៏បានចុះសិក្សា និងប្រមូលទិន្នន័យពីស្ថានីយចំនួនពីរ (២) ទៀតគឺស្ថានីយទឹកស្អាតកោះសុទិន និងស្ថានីយទឹកស្អាតកំចាយមារ។



## ៤. ការសិក្សាពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើផ្នែកហិរញ្ញវត្ថុរបស់អាជីកម្មផ្គត់ផ្គង់ទឹកស្អាត

នៅត្រីមាសទី៣នេះ គម្រោងបានសហការជាមួយប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន២ បន្ថែមទៀតគឺ ស្ថានីយទឹកស្អាតព្រៃករាំង និងស្ថានីយទឹកស្អាតកំចាយមារ ដើម្បីសិក្សាអំពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើផ្នែកហិរញ្ញវត្ថុរបស់អាជីកម្មផ្គត់ផ្គង់ទឹកស្អាត។



គម្រោងក៏បានស្នើសុំកិច្ចសហការបន្ថែមពីប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន៥ រួមមាន៖

១. ស្ថានីយទឹកស្អាត ឡេង ខៀវ ព្រៃកអំបិល ២. ស្ថានីយទឹកស្អាតបរវេល ៣. ស្ថានីយទឹកស្អាត ខោ ប៊ុនហ៊ាត ៤. ស្ថានីយទឹកស្អាតកំពង់ចំលង ៥. ស្ថានីយទឹកស្អាតបែកចាន ដែលធ្លាប់បានសិក្សាអំពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើផ្នែកហិរញ្ញវត្ថុរបស់អាជីកម្មផ្គត់ផ្គង់ទឹកស្អាតកន្លងមក ដើម្បីបន្ថែមទិន្នន័យសិក្សាចាប់ពីខែមីនា ឆ្នាំ២០២១ ដល់ខែកញ្ញា ឆ្នាំ២០២១។

## ៥. កិច្ចប្រជុំ ពិគ្រោះយោបល់រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន

យោងលើភាពជោគជ័យនៃការរៀបចំកិច្ចប្រជុំ ពិគ្រោះយោបល់រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ២លើករួចមកហើយ និងផ្អែកលើស្ថានភាពរីករាលដាលនៃជំងឺកូវីដ-១៩ គម្រោងសម្រេច រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ(ថ្នាក់ខេត្ត) តាមប្រព័ន្ធអនឡាញ(Zoom Call) នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ សម្រាប់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ទូទាំងខេត្តព្រៃវែង។ កិច្ចប្រជុំនេះមានគោលបំណងដូចខាងសក្រោម៖

1. ជំរុញការប្រាស្រ័យទាក់ទង ទំនាក់ទំនង និងកិច្ចសហការរវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន (PWOs) និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាជាមួយដៃគូពាក់ព័ន្ធគម្រោង WASH-FIN ក្នុងខេត្តព្រៃវែងដើម្បីស្វែងរកការគាំទ្រក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនមូលដ្ឋាននៅក្នុងតំបន់គ្របដណ្តប់ដោយ ប្រកាសអនុញ្ញាតឱ្យផ្គត់ផ្គង់ទឹកស្អាត(អាជ្ញាបណ្ណ)។
2. ពិភាក្សា និងកំណត់ដំណោះស្រាយរបស់មូលដ្ឋានចំពោះបញ្ហា និងការប្រឈមនានាដែលរារាំងដល់ការដែលធ្វើឱ្យប្រសើរឡើងនូវការទទួលបានទឹកស្អាតរបស់ប្រជាជនក្នុងតំបន់មានប្រកាសអនុញ្ញាតផ្គត់ផ្គង់ទឹកស្អាត(អាជ្ញាបណ្ណ)។

3. ប្រមូលធាតុចូលសម្រាប់ការអភិវឌ្ឍគោលនយោបាយទឹកស្អាត និងអនាម័យ(ជាពិសេសការផ្តល់សេវាទឹកស្អាតតាមបណ្តាញ) ការវាយតម្លៃ និងកំណត់មុខងារស្តីពីការគ្រប់គ្រងសេវាផ្គត់ផ្គង់ទឹកស្អាត។

ជាលទ្ធផលកិច្ចប្រជុំ មានកិត្តិយសដែលមានគណអធិបតីរួមមានៈឯកឧត្តម តន់ សុខជា អគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧវបន លោក ជ័យ សម្បត្តិផល្លា ប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ នៃលេខាធិការដ្ឋាន គ.ជ.អ.ប ឯកឧត្តម សួន សុម៉ាលីន អភិបាលរងខេត្ត និងជាតំណាងគណៈអភិបាលខេត្តព្រៃវែង និងតំណាងមកពីលេខាធិការដ្ឋាន គ.ជ.អ.ប ចំនួន ៣នាក់ ក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ចំនួន ៣នាក់ លោកអភិបាលរងខេត្តចំនួន ១នាក់ នាយកទីចាត់ការផែនការនិងគាំទ្រឃុំ សង្កាត់ សាលាខេត្តចំនួន ១នាក់ តំណាងរដ្ឋបាលស្រុកចំនួន ៧ស្រុក (៨នាក់) មន្ទីរជំនាញក្នុងខេត្តចំនួន ៦ស្ថាប័ន (៨នាក់) អង្គការ និងដៃគូអភិវឌ្ឍន៍ចំនួន ៧ស្ថាប័ន (៩នាក់) ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ១៤ស្ថានីយ (១៧នាក់) ដែលអញ្ជើញមកពីខេត្តព្រៃវែង ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ធំ បុគ្គលិកគម្រោង WASH-FIN ចំនួន ៦នាក់ ព្រមទាំងប្រធានក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគមចំនួន ៩នាក់ ដែលមានចំនួនសរុប ៦៥នាក់។




## ៦. ការជ្រើសរើសបុគ្គលិក

នៅក្នុងត្រីមាសទី៣នេះ សមាគមបានជ្រើសរើសបុគ្គលិកថ្មីចំនួនពីរ (២)

1. អ្នកស្រី ដួក ម៉ារី ជាមន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុដែលបានចាប់ផ្តើមធ្វើការនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១។
2. កញ្ញា ហេង រចនា ជាវិស្វករទឹកស្អាតដែលនឹងចាប់ផ្តើមធ្វើការនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១។

# គម្រោងឧបត្ថម្ភធនលើថ្លៃ តភ្ជាប់ទឹកស្អាតសម្រាប់គ្រួសារក្រីក្រ១ និងក្រីក្រ២ (EMW)

## ១. កិច្ចប្រជុំផ្សព្វផ្សាយគម្រោង

ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២១ សមាគមបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយគម្រោងស្តីពី «ការឧបត្ថម្ភធនលើថ្លៃតភ្ជាប់ទឹកស្អាតសម្រាប់គ្រួសារក្រីក្រ១ និងក្រីក្រ២»។ សិក្ខាសាលាមានអ្នកចូលរួមចំនួន ១៥នាក់ ក្នុងនោះមានតំណាងមកពីអង្គការលោកខាងលិចជួបលោកខាងកើត បុគ្គលិកសមាគម អាជ្ញាធរឃុំ និងប្រតិបត្តិករទឹកស្អាតចំនួន៣ស្ថានីយ គឺ១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំសំរោង ២.ស្ថានីយផ្គត់ផ្គង់ទឹកស្អាតមហាលាភក្បាលបឹង និងទី៣.ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ពង្រមហាលាភ។ សិក្ខាសាលារៀបចំឡើងនៅ ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំសំរោង ខេត្តព្រៃវែង ក្រោយពេលបញ្ចប់កិច្ចប្រជុំ ស្ថានីយទាំង៣ បានចុះកិច្ចព្រមព្រៀងអនុវត្តន៍គ្រោងឧបត្ថម្ភធនលើថ្លៃតភ្ជាប់ទឹកស្អាតសម្រាប់គ្រួសារក្រីក្រ១ និងក្រីក្រ២។



## ២. កិច្ចប្រជុំឆ្លុះបញ្ចាំងស្តីពីការអនុវត្តគម្រោង

ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ សមាគម បានរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងស្តីពីការអនុវត្តគម្រោង «ការផ្តល់ឧបត្ថម្ភធនលើថ្លៃតភ្ជាប់ទឹកស្អាត សម្រាប់គ្រួសារមានប័ណ្ណក្រីក្រ ១ និងក្រីក្រ ២ » ក្រោមជំនួយឧបត្ថម្ភរបស់អង្គការលោកខាងលិច ជួបលោកខាងកើត (EMW) តាមប្រព័ន្ធអនឡាញ (Zoom Call) ។ កិច្ចប្រជុំឆ្លុះបញ្ចាំងនេះ មានការចូលរួមពីនាយកប្រតិបត្តិ សមាគម ប្រធានកម្មវិធីទឹកស្អាត និងអនាម័យ EMW បុគ្គលិកសមាគម និងតំណាងប្រតិបត្តិករទឹកស្អាតឯកជន។ គម្រោងនឹងជ្រើសរើសប្រតិបត្តិករឆ្នើមចំនួន៣ ដើម្បីផ្តល់រង្វាន់ លើកទឹកចិត្តក្នុងការខិតខំតភ្ជាប់បណ្តាញទឹកស្អាតជូនគ្រួសារក្រីក្របានប្រើប្រាស់ទឹកស្អាត។

## ៣. ការចុះផ្ទៀងផ្ទាត់ទិន្នន័យ

ក្នុងត្រីមាសទី៣ នេះសមាគមបានចុះទៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំចាយមារ ស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំការលើ និងស្ថានីយផ្គត់ផ្គង់ទឹកស្អាត ក្រូចឆ្មារ ដើម្បីផ្ទៀងផ្ទាត់ ចំនួនគ្រួសារក្រីក្រដែលបានតភ្ជាប់បណ្តាញទឹកស្អាត។ ជាលទ្ធផល ២៤៧គ្រួសារបានតភ្ជាប់ទឹកស្អាតប្រើប្រាស់។




**គម្រោង ការបង្កើននូវភាពធន់ នឹងអាកាសធាតុសម្រាប់ការផ្គត់ផ្គង់ទឹកស្អាត ដែលនៅក្នុងឃុំដែលមានហានិភ័យប្រឈមទៅនឹងបម្រែបម្រួលអាកាសធាតុ** (UNICEF)

នៅ ត្រីមាសទី៣ គម្រោងបានអនុវត្តសកម្មភាពសំខាន់ដូចខាងក្រោម៖

### ១. ការផ្សព្វផ្សាយ

កាលពីថ្ងៃទី៤ ខែសីហា ឆ្នាំ២០២១ សមាគមបានរៀបចំប្រជុំផ្សព្វផ្សាយគម្រោង«ការបង្កើននូវភាពធននឹងការបម្រែបម្រួលអាកាសធាតុសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត» ក្រោមជំនួយឧបត្ថម្ភពីអង្គការយូនីសេហ្វ (UNICEF) និងកិច្ចសហប្រតិបត្តិការពីអគ្គនាយកដ្ឋានទឹកស្អាត នៃក្រសួងឧស្សាហកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍។តាមប្រព័ន្ធអនឡាញ (Zoom Call) គោលបំណងនៃកិច្ចប្រជុំគឺដើម្បីឱ្យប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតនៅក្នុងតំបន់គោលដៅយល់ ច្បាស់ពីគម្រោង និងដាក់ពាក្យស្នើរសុំចូលគម្រោង។

អ្នកចូលរួមក្នុងកិច្ចប្រជុំនេះរួមមាន៖ តំណាង ក្រសួង មន្ទីរឧស្សាហកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍ ខេត្តតាកែវ មន្ទីរឧស្សាហកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ តំណាង UNICEF) បុគ្គលិកសមាគម និងប្រតិបត្តិករទឹកស្អាតមកពីស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ និងស្រុកបូរីជលសារ ខេត្តតាកែវ។ ជាលទ្ធផល ស្ថានីយចំនួន ៦ បានដាក់ពាក្យសុំចូលគម្រោង។

## ២. ការអនុវត្តន៍គម្រោង

ក្រុមការងារបច្ចេកទេសសមាគម ដោយមានការចូលរួមពីមន្ត្រីក្រសួងឧវបន បានចុះប្រមូលព័ត៌មាន និងសិក្សាលម្អិតពីតម្រូវការរបស់ស្ថានីយទាំង៦ ហើយគម្រោងចូលរួមឧបត្ថម្ភធនដល់ស្ថានីយចំនួន៥។




# ការកសាងសមត្ថភាពសមាជិកសមាគម

## ១. វគ្គបណ្តុះបណ្តាល

នៅត្រីមាសនេះ សមាគមបានប់វគ្គបណ្តុះបណ្តាលៈ

➢ ព្រឹកថ្ងៃសុក្រ ទី២៣ ខែកក្កដា ឆ្នាំ២០២១ សមាគម បានរៀបចំវគ្គបណ្តុះ បណ្តាលស្តីពី«ការធ្វើតេស្តគុណភាពទឹកស្អាតសម្រាប់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត» តាមប្រព័ន្ធអនឡាញ(Zoom call) ។ អ្នកចូលរួមវគ្គបណ្តុះ បណ្តាលសរុប ៨៦រូប ដែលជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងអ្នកបច្ចេកទេស ។ វគ្គបណ្តុះបណ្តាលផ្តោតលើបីចំណុចសំខាន់ៗ ដូចខាងក្រោមៈ

១. រៀបរាប់ពីប៉ារ៉ាម៉ែត្រដែលត្រូវធ្វើតេស្តគុណភាពទឹកប្រចាំថ្ងៃ ប្រចាំត្រីមាស និងប្រចាំឆ្នាំ
២. ស្វែងយល់ពីការកំណត់ថ្លៃលើការតេស្តប៉ារ៉ាម៉ែត្រនីមួយៗ
៣. អនុវត្តការកត់ត្រាលទ្ធផលតេស្ត និងបង្កើនការយល់ដឹងពីសារៈប្រយោជន៍នៃការកត់ត្រានេះ។

# កិច្ចសហការជាតិ

នៅត្រីមាសទី៣នេះសមាគមបានធ្វើកិច្ចសហាករជាមួយដៃគូក្នុងស្រុក និងក្រសួងដូចខាងក្រោមៈ

➢ នៅថ្ងៃអង្គារ ទី៣ ខែសីហា ឆ្នាំ២០២១ ចូលរួម ក្រោមកិច្ចសហការរបស់អគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សមាគមបានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពី«បទពិសោធន៍នៃការធ្វើទស្សនកិច្ចសិក្សានៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត តាមប្រព័ន្ធអនឡាញ (Zoom call) ជូនដល់ថ្នាក់ដឹកនាំក្រសួង មន្ទីរ រដ្ឋាករទឹកសាធារណៈ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន សរុប ១២០ នាក់។

➢ ថ្ងៃអង្គារ ទី២៧ ខែសីហា ឆ្នាំ២០២១ សមាគមបានចូលរួមជាវាគ្មិនក្នុងកម្មវិធីកិច្ចសន្ទនាAVIគោលដៅអភិវឌ្ឍន៍ដោយចីរភាពស្តីពីទឹកស្អាត អនាម័យ និងការអភិវឌ្ឍន៍ជនបទតាមប្រព័ន្ធអនឡាញ (Zoom call)។

➢ កាលពីថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២១ សមាគមបានរៀបចំកិច្ចពិភាក្សាតុមូលតាមប្រព័ន្ធអនឡាញ (Webinars) ស្តីពី «កម្ចីសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម»។ ក្នុងគោលបំណងដើម្បីឲ្យធនាគារធ្វើបទបង្ហាញអំពីការផ្តល់កម្ចី ទៅដល់សហគ្រាសធុនតូច និងមធ្យម ជាពិសេសចំពោះប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតដែលជាសមាជិកសមាគម។ កម្មវិធីនេះមានការចូលរួមពី ធនាគារសហគ្រាសធុនតូច និងមធ្យម(SME Bank) ធនាគារកាណាឌីយ៉ា ក.អ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ កម្មវិធីនេះបានផ្សាយផ្ទាល់តាមប្រព័ន្ធ Zoom និងទំព័រហ្វេសប៊ុកផេករបស់សមាគម។

## កិច្ចសហការអន្តរជាតិ

នៅត្រីមាសទី៣នេះ សមាគមបានចូលរួមក្នុងភាពជាដៃគូរជាមួយការងារបណ្តាញរបស់ដៃគូអភិវឌ្ឍន៍អន្តរជាតិរួមមាន៖

- ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២១ លោកនាយកប្រតិបត្តិ សមាគម បានចូលរួមក្នុងវេទិកាសន្ទនាលើឧស្សាហកម្មទឹកនៅថ្នាក់តំបន់ "Regional Water Industry Expert Dialogue" ស្តីពីការចែករំលែកមេរៀនបទពិសោធន៍លើផលប៉ះពាល់ពីជំងឺរាតត្បាត កូវីដ-១៩ ជាសកលមកលើឧស្សាហកម្មទឹក ដែលរៀបចំដោយអង្គការទឹកអាស៊ី(ASIA WATER)តាមប្រព័ន្ធអនឡាញ(Webinars)។
- ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២១ លោកនាយកប្រតិបត្តិសមាគម បានធ្វើបទបង្ហាញស្តីពីសមាគម និងឱកាសវិនិយោគលើវិស័យទឹកស្អាតនៅកម្ពុជា ក្នុងវេទិកា **SgWX Water Utilities Series – Water Sector Opportunities in Cambodia**។
- ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ សមាគមទឹកអូស្រ្តាលី និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានរៀបចំសិក្ខាសាលាចែករំលែកចំណេះដឹង អូស្រ្តាលី-កម្ពុជា ស្តីពី «ការវាយតម្លៃអាងប្រព្រឹត្តកម្ម (ការសម្អាតទឹក) និងការអនុវត្តនីតិវិធីដែលល្អបំផុត» តាមប្រព័ន្ធអនឡាញ(Zoom Call)។

## ការបម្រុងសម្រួលសមាជិក

នៅក្នុងត្រីមាសទី៣ សមាគមបានដោះស្រាយបញ្ហាសមាជិកដូចខាងក្រោម៖

សមាគមបានសហការជាមួយ មន្ទីរឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ស្ពឺ ចុះទៅពិនិត្យដល់ទីតាំងរាយបណ្តាញបំពង់នាំទឹកផៅពីស្រះសហគមន៍ដោយឆ្លងកាត់ដីឡូត៍ឯកជន (ពីមុនជាភ្លឺស្រែសហគមន៍) ក្នុងឃុំក្សេមក្សាន្ត ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ និងបានផ្តល់ជាអនុសាសន៍ណែនាំដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតក្នុងការដោះស្រាយបញ្ហា។